ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃព្រហស្បតិ៍ ៣ រោច ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ជំនួបរវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ ឯកឧត្តម Justin Kevin Whyatt ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលីប្រចាំប្រទេសកម្ពុជា

នារសៀលថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី កម្ពុជា-អូស្ត្រាលី ជាមួយឯកឧត្តម Justin Kevin Whyatt ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា ដែលទើបចូលកាន់តំណែង។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម Justin Kevin Whyatt ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា។ នៅក្នុងជំនួបនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីបានរំលឹកឡើងវិញពីសមិទ្ធផលនានាដែលសម្រេចបាន កើតចេញពីចំណងមិត្តភាពនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនាពេលកន្លងមក។ ទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរនេះ បានផ្តល់ផ្លែផ្កាគួរជាទីពេញចិត្តទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ, កិច្ចសហប្រតិបត្តិការតាមវិស័យរវាងរដ្ឋ និងរដ្ឋ និងពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរដែលត្រូវបានពង្រឹង និងពង្រីកឥតឈប់ឈរ។ ជាក់ស្តែង មានកម្មវិធី និងគម្រោងជាច្រើនដែលបាន និងកំពុងអនុវត្តក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលអូស្ត្រាលីដូចជាៈ កម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC), កម្មវិធីវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (3i), កម្មវិធីភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ (P4I), កម្មវិធីភាពជាដៃគូមេគង្គ-អូស្ត្រាលី (MAP), និងកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ACCESS)។ ចុងក្រោយនេះគឺ កម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAP RED) ដែលមានទំហំហិរញ្ញប្បទានឥតសំណងប្រមាណ ៨៧ លាន ដុល្លារអូស្ត្រាលី (ត្រូវនឹងប្រមាណ ៦៥ លានដុល្លារ

អាមេរិក)។ ទន្ទឹមនេះ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរបានកើនឡើងជាលំដាប់ពីចំនួន ២០៥ លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ដល់ ៥២៣ លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០២២។

ជាមួយគ្នានេះដែរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនអូស្ត្រាលី ដែលបានបន្តផ្តល់ហិរញ្ញប្បទានឥតសំណង និងជំនួយបច្ចេកទេស ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជាពិសេស ជំនួយជាវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលបានរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត ភាពប៉ិនប្រសប់ និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។

ជាការឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី** មានក្តីសោមនស្សរីករាយដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅប្រទេសកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានវាយតម្លៃខ្ពស់ ចំពោះសមិទ្ធិផលដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន ជាពិសេស ឯកឧត្តមបានមើលឃើញជាក់ស្តែងអំពីការអភិវឌ្ឍលើគ្រប់វិស័យ, ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងការអនុវត្តកម្មវិធីគាំពារសង្គមប្រកបដោយជោគជ័យ ទោះបីស្ថិតក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ និងផលវិបាកនៃសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន។ ឯកឧត្តមនឹងបន្តពូនជ្រុំចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា-អូស្ត្រាលី ឱ្យកាន់តែរឹងមាំ និងជ្រាលជ្រៅថែមទៀត សំដៅរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅកម្ពុជា។ ជាមួយគ្នានេះ កម្មវិធី CAP RED ដែលត្រូវបានសម្ពោធដាក់ឱ្យដំណើរការកាលពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០២២ កន្លងមក បានបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការបន្តគាំទ្រដល់ការអភិវឌ្ឍនៅកម្ពុជា។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណចំពោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** Justin Kevin Whyatt ដែលបន្តគាំទ្រការអភិវឌ្ឍនៅកម្ពុជា និងជំរុញកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ កម្ពុជា-អូស្ត្រាលី និងជូនពរចំពោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** សូមមានសុខភាពល្អ និងបំពេញបេសកកម្មការទូតនៅកម្ពុជាប្រកបដោយជោគជ័យ៕